# បទបង្ហាញស្តីពី

# ការចងក្រងក្រុមកសិករសិក្សាខ្នាតតូច

## Smallholder Learning Group (SLG)

## សម្រាប់កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នៅនឹងការប្រែប្រួលអាកាសធាតុ ( ASPIRE )

បទបង្ហាញដោយ ក្រុមការងារកម្មវិធី ASPIRE មន្ទីរកសិកម្មខេត្តពោធិ៍សាត់

ពោធិ៍សាត់ ថ្ងៃទី ២០-២២ ខែ មេសា ឆ្នាំ២០១៦

# ក. ការចុះរៀបចំប្រជុំផ្សព្វផ្សាយថ្នាក់ភូមិ

1. គោលបំណង និងគោលដៅនៃការបង្កើតក្រុម
2. អត្តន័យក្រុម
3. គុណសម្បត្តិ និងគុណវិបត្តិក្រុម
4. កំណត់ចំណាត់ថ្នាក់ធនធានក្នុងភូមិ
5. លក្ខណៈវិនិច្ឆ័យអ្នកចូលរួម (កំណត់អ្នកចូលរួម ២៥នាក់)

## ១. គោលបំណង និងគោលដៅ

ការចងក្រងក្រុមកសិករសិក្សាខ្នាតតូច នៅតាមភូមិ ឃុំគោលដៅ ដើម្បីជំរុញការយល់ដឹងនិងបង្កើនសមត្ថភាពរបស់ក្រុមកសិករពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើផលិតកម្មកសិកម្មនិងជីវភាពរស់នៅ និងដំណោះស្រាយ និងតម្រូវការបច្ចេកទេសកសិកម្ម និងជម្រើសនានាដើម្បីបន្សាំ និងបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

**គោលបំណង** បង្កើនប្រសិទ្ធភាពនៃការចូលរួមរបស់កសិករបង្ករភាពងាយស្រួលក្នុងការផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូលគ្រួសារតាមរយៈ សិក្សាខ្នាតតូច ការផ្លាស់ប្តូរបទពិសោធន៍ និងបង្កភាពងាយស្រួលក្នុងការទំនាក់ទំនង។

# ១. គោលបំណង និងគោលដៅ (ត)

ឯកសារការចងក្រងក្រុមកសិករសិក្សាខ្នាតតូចមាន**គោលដៅ**លម្អិតដូចខាងក្រោម៖

- ដើម្បីជួយណែនាំដល់មន្ត្រីផ្សព្វផ្សាយកសិកម្មក្នុងការបង្កើតក្រុមកសិករសិក្សាខ្នាតតូច
- បង្កើតនូវក្រុមកសិករសិក្សាខ្នាតតូចដ៏រឹងមាំដែលពួកគេអាចយល់ដឹងអំពីរបៀបក្នុងការគ្រប់គ្រងដោយខ្លួនឯងនៅក្នុងតំបន់គោលដៅរបស់កម្មវិធី
- កំណត់តម្រូវការជម្រើសបច្ចេកទេស និងបច្ចេកវិទ្យា និងការកសាងសមត្ថភាពរបស់កសិករ ដើម្បីបន្សាំ និងពង្រឹកភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅតាមភូមិ ឃុំគោលដៅ
- ដើម្បីជួយពង្រឹងអំណាចក្រុមកសិករសិក្សាខ្នាតតូចនិងមាននិរន្តរភាពក្នុងការបង្កើនជីវភាពស់នៅ។